**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| **តុលាការខេត្តកំពង់ធំ** |
| <u>សាលក្រម</u> |
| លេខ ១៥ "ក" ចុះថ្ងៃទី ២៦ |
| ខែ ឧសភា ឆ្នាំ ២០០៦ |
| <u>សំណុំរឿង</u> |
| លេខ ២៦ ចុះថ្ងៃទី ២១ |
| ខែ មីនា ឆ្នាំ ២០០៦ |

សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ តទៅ ដោយគ្មានគូភាគីទទួលតវ៉ាតាមកំណត់ច្បាប់ ។
កំពង់ធំ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៦
**ក្រឡាបញ្ជីតុលាការខេត្ត** [redacted]

**នាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ:

<u>ចៅក្រមជំនុំជំរះ</u>

លោក [redacted]

<u>តំណាងអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

សំណុំរឿងរដ្ឋប្បវេណីលេខ ២៦ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង <u>ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធ</u> ។

-រវាងដើមចោទ អ សយ ភេទប្រុស អាយុ ២៨ឆ្នាំ របររកស៊ីជាងទង ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ ខ មឱ មានកូន ០២នាក់ ឪពុកឈ្មោះ អ ឧ (រ) ម្តាយឈ្មោះ ស អ "រ" ។

-និង ចុងចម្លើយឈ្មោះ ខ មឱ ហៅ មុំ ភេទស្រី អាយុ ២៧ឆ្នាំ របររកស៊ីលក់ដូរ សព្វថ្ងៃនៅភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ប្តីឈ្មោះ អ សយ មានកូន ០២នាក់ ឪពុកឈ្មោះ ខ ឧ (រ) ម្តាយឈ្មោះ គ ណស "រ" ។

<u>**ឯរឿងហេតុមានដូចតទៅ**</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ដើមចោទឈ្មោះ អ សយ បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយនាង ខ មឱ ឆ្នាំ ២០០១ ត្រឹមត្រូវតាមច្បាប់ រួមរស់នៅជាមួយគ្នាបានកូនប្រុស ០២នាក់ ។ ការរស់នៅរួមគ្នាជាប្តីប្រពន្ធពុំសូវបានសេចក្តីសុខទេ ចេះជាមានតំនិតទំនាស់គ្នារហូតដល់ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ខ្លួន និង ប្រពន្ធបានព្រមព្រៀងឯកភាពលែងលះគ្នា និង បែងចែកទ្រព្យសម្បត្តិតាមកំណត់ហេតុ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ មានផ្តិតមេដៃត្រឹមត្រូវ ហើយក៏បានបែកលំនៅសង្វាសពីគ្នារហូតដល់សព្វថ្ងៃទើបប្តឹងសុំលែងលះមកតុលាការនេះ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ២១៥ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ របស់តុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមលេខ ២១៦ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ របស់តុលាការខេត្តកំពង់ធំ ។

<u>នាពេលសវនាការ</u>

-ដើមចោទឈ្មោះ **អ សយ** បានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ម ឌ ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ២០០១ ហើយនៅរួមរស់ជាមួយគ្នាបានកូនប្រុស ០២នាក់ ទី១ ឈ្មោះ ឌ លចា អាយុ ០៤ឆ្នាំ ទី២ ឈ្មោះ ឌ លចាន អាយុ ០៦ខែ ។ បន្ទាប់ពីរៀបការរួចមកការរួមរស់នៅជាមួយគ្នាចេះតែរកាំរកូសជាញឹកញាប់ មកដល់ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ខ្លួនហូបបាយពេលថ្ងៃរួចមុនពេលដើរចេញមកខាងមុខផ្ទះ ស្រាប់តែឃើញដបទឹកសុទ្ធដែលប្រពន្ធបានដាក់លក់នោះនៅចំពន្លឺថ្ងៃក្តៅ ក៏ស្រែកសួរទៅប្រពន្ធថា ម្តេចឯងដាក់ដបទឹកសុទ្ធលក់ឱ្យត្រូវថ្ងៃ ភ្នែកក៏មិនមើល ពេលប្រពន្ធឆ្លើយថា ត្រូវថ្ងៃឯណា ថែមទាំងប្រឡោតស្រែកយ៉ាងខ្លាំង និងលើកដៃចង្អុលចំមុខ ហើយស្រែកថា រឿងរ៉ាវពីមុនមិនទាន់រួចខ្លួនផង មកចង់បង្ករឿងថ្មីទៀត ពេលនេះខ្លួនខឹងក៏ស្ទុះទៅទះប្រពន្ធមួយដៃ រួចក៏ជិះម៉ូតូចេញពីផ្ទះភ្លាម ។ លុះមកដល់ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ឪពុកក្មេកឈ្មោះ ខ ឌ បានហៅខ្លួន និង ប្រពន្ធមកជួបចំពោះមុខគាត់ ហើយអោយខ្លួន និង ប្រពន្ធធ្វើកិច្ចសន្យាលែងលះគ្នា និង បែកចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ។ ពេលនោះខ្លួន និង ប្រពន្ធបានព្រមព្រៀងឯកភាពគ្នាដោយស្ម័គ្រចិត្តលែងលះគ្នា និង ឯកភាពបែកចែកទ្រព្យសម្បត្តិរួមមានធ្វើកំណត់ហេតុផ្តិតមេដៃត្រឹមត្រូវចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលមានអ្នកដឹងលឺចំនួន ០៦នាក់ ចំណែកទ្រព្យសម្បត្តិដើមគ្មានទេ សំណូមពរតុលាការសុំអោយដាច់សមគ្គសង្វាសពីប្រពន្ធ និង សុំចែងចែកកូនតាមច្បាប់ ចំណែកឯទ្រព្យសម្បត្តិរួមបានបែងចែកគ្នានៅមូលដ្ឋានអស់ហើយមិនមានអ្វីពាក់ព័ន្ធទៀតទេ ។

-ចុងចម្លើយឈ្មោះ **ខ មឌ** បានឆ្លើយបញ្ជាក់ថា ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយប្តីឈ្មោះ **អ សយ** ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ២០០១ រួមរស់នៅជាមួយគ្នាមានកូនប្រុស ០២នាក់ ទី១ ឈ្មោះ **ឌ លចា** អាយុ ០៤ឆ្នាំ. ទី២ ឈ្មោះ **ឌ លចាន** អាយុ ០៦ខែ ។ កន្លងមកការរួមរស់នៅជាមួយគ្នាចេះតែរកាំរកូសជាញឹកញាប់ អាស្រ័យដោយការរកស៊ីលក់ដូររាល់ថ្ងៃ ប្តីមិនមានទំនុកចិត្តលើខ្លួនជាប្រពន្ធទេ គ្មានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធឡើយ ។ លុះមកដល់ចុងខែ មករា ឆ្នាំ ២០០៦ វេលាម៉ោង ៧:០០នាទីយប់ពេលហូបបាយជុំគ្នាស្រាប់តែកូន និង ប្អូនស្រីខ្លួនប្រឡែងគ្នាលេង ហើយកូនខ្លួនយំ ប្តីខឹងស្ទុះទៅវាយកូន រួចបោកចានបាយទៅលើវង់បាយ ដែលកំពុងហូបបាយទាំងអស់គ្នាមានឪពុកម្តាយខ្លួនហូបផងនាំឱ្យប៉ះពាល់ដល់កិត្តិយសអ្នកមានគុណយ៉ាងធ្ងន់ធ្ងរ មូលហេតុទាំងនេះហើយធ្វើឱ្យខ្លួនអស់មនោសញ្ចេតនានឹងរួមរស់នៅជាប្តីប្រពន្ធតទៅទៀត ។ ចំពោះទ្រព្យសម្បត្តិដើមមានមាសសុទ្ធចំនួន ០៩ជីបានដាក់បញ្ចូលជាទ្រព្យសម្បត្តិរួមដែលរកស៊ីសព្វថ្ងៃ ហើយទ្រព្យសម្បត្តិរួមបានឯកភាពបែកចែករួចហើយមានកំណត់ហេតុព្រមព្រៀង ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ មានផ្តិតមេដៃត្រឹមត្រូវ ។ សំណូមពរសុំលែងលះពីប្តីតាមច្បាប់តទៅ សុំគ្រប់គ្រងកូន ០២នាក់ សុំទាមទារមាសសុទ្ធ ០៩ជីជាទ្រព្យសម្បត្តិដើម មិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ ។

<u>តំណាងអយ្យការបានធ្វើសន្និដ្ឋានថា</u> :

ចំពោះរឿងនេះជាប្រភេទរឿងរដ្ឋប្បវេណី អយ្យការទុកឲ្យតុលាការសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ
-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តកំពង់ធំ**

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ដើមចោទឈ្មោះ **អ សយ** មាន លក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ **អ សយ** បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ **ខ មឌ** ដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយនាង **ខ មឌ** ពីឆ្នាំ ២០០១ ត្រឹមត្រូវតាមច្បាប់រួមរស់នៅជាមួយគ្នាបានកូនប្រុស ០២នាក់ ។ ការរួមរស់នៅរួមគ្នាជាប្តីប្រពន្ធ ពុំសូវមានសេចក្តីសុខទេ ចេះតែមានគំនិតទំនាស់គ្នា រហូតដល់ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ខ្លួន និង ប្រពន្ធបានព្រមព្រៀងឯកភាពលែងលះគ្នា និង បែងចែកទ្រព្យសម្បត្តិតាមកំណត់ហេតុចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ មានផ្តិតមេដៃត្រឹមត្រូវ ហើយក៏បានបែកលំនៅសង្វាសពីគ្នារហូតសព្វថ្ងៃ ទើបប្តឹងសុំលែងលះមកតុលាការនេះ ។

-យល់ឃើញថា : គូភាគីពិតជាបានរៀបអាពាហ៍ពិពាហ៍ ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ រួមរស់នៅមួយគ្នាមានកើតរឿងរកាំរកូសឈ្លោះទាស់ទែងគ្នា រហូតបានឯកភាពលែងលះគ្នា និង បែងចែកទ្រព្យសម្បត្តិរួមគ្នារួចអស់ហើយ ព្រមទាំងអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា : គូភាគីមានកូន ០២នាក់ ១-ឈ្មោះ **ឆ លហ** អាយុ ០៤ឆ្នាំ, ២- ឈ្មោះ **ឆ លហន** អាយុ ០៦ខែ ចុងចម្លើយបានទាមទារសុំគ្រប់គ្រងថែរក្សា និង មិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ តុលាការពិចារណាតាមច្បាប់ ។

-យល់ឃើញថា : ចុងចម្លើយឈ្មោះ **ខ មឌ** បានទាមទារទ្រព្យសម្បត្តិដើមមាស ០៩ជីថា ខ្លួនបានដាក់បញ្ចូលទៅក្នុងទ្រព្យសម្បត្តិរួម ដែលបានព្រមព្រៀងឯកភាពបែងចែកគ្នាតាមកំណត់ហេតុស្តីពីការព្រមព្រៀងលែងលះគ្នា និង ការបែងចែកទ្រព្យសម្បត្តិ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ រួមមកហើយនោះពុំគួរអោយជឿបានឡើយ ព្រោះគ្មានភស្តុតាង និង សាក្សីមានបញ្ជាក់អោយតុលាការទេ ។

-យល់ឃើញថា : ទ្រព្យសម្បត្តិរួមរបស់គូភាគី បានព្រមព្រៀងឯកភាពបែងចែកគ្នានៅមូលដ្ឋានអស់ហើយ ដូចមានក្នុងកំណត់ហេតុស្តីពីការព្រមព្រៀងលែងលះគ្នា និង បែងចែកទ្រព្យសម្បត្តិចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។ នោះតុលាការមិនលើកយកមកពិចារណាទៀតទេ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ដើមចោទឈ្មោះ **អ សយ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ **អ សយ** និង ចុងចម្លើយឈ្មោះ **ខ មឌ** ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។

ដាក់កំហុសលើដើមចោទ ។

៣-ឱ្យឈ្មោះនាង **ខ មឌ** ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់ ០២នាក់ ១-ឈ្មោះ **ឧ លមហ** ភេទប្រុស អាយុ ០៤ឆ្នាំ. ២-ឈ្មោះ **ឧ លមេឌ** ភេទប្រុស អាយុ ០៦ខែឱ្យទៅចុងចម្លើយឈ្មោះ **ខ មឌ** គ្រប់គ្រងចិញ្ចឹមថែរក្សា ។ ទុកសិទ្ធិឱ្យដើមចោទទៅសួរសុខទុក្ខកូនបាន តាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តីពន្ធហ្នឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០រ០០ សរុប ៧.០០០រ០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់រួចហើយ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០២ខែតាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្ត**

[redacted]